**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ**
**THE STUDENT MOVEMENT FOR DEMOCRACY**

លេខ៖ ០០២២/២០ ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២០

# សេចក្តីថ្លែងការណ៍
## ថ្កោលទោសរដ្ឋាភិបាលកម្ពុជា
## ករណីចាប់ឃាត់ខ្លួនសកម្មជនពលរដ្ឋសកម្មដើម្បីយុត្តិធម៌

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមថ្កោលទោសអាជ្ញាធររដ្ឋាភិបាលកម្ពុជា ដែលបានចាប់ឃាត់ខ្លួនព្រះភិក្ខុ **គើត សារ៉ាយ** និង លោក **មាន ព្រហ្មមុនី** ជាអ្នកដឹកនាំ **ពលរដ្ឋសកម្មដើម្បីយុត្តិធម៌** នៅទីស្នាក់ការសមាគមសម័ន្ធនិស្សិតបញ្ញវន្តខ្មែរ ក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២០ នៅម៉ោង០១:៣០នាទី រសៀល។

កម្លាំងឯកសណ្ឋានស៊ីវិល ដែលមិនបង្ហាញអត្តសញ្ញាណជាសមត្ថកិច្ចប្រមាណ២០នាក់ រួមមានព្រះសង្ឃផងដែរ បានសម្រុកចូលស្នាក់ការរបស់សមាគម និងចាប់ទាញទាំងបង្ខំ នាំយកព្រះកាយភិក្ខុ **គើត សារ៉ាយ** និងលោក **មាន ព្រហ្មមុនី** ទ្បើងទ្បានទៅទិសផ្សេងគ្នា ដោយពុំបានបង្ហាញនូវដីកាចាប់ខ្លួនដល់សាមីខ្លួន ។ ការចាប់ខ្លួននេះ កើតឡើង បន្ទាប់ពីអ្នកដឹកនាំទាំងពីររូប បានប្រកាសជំហរមិនងាករេ ក្នុងការរៀបចំបាតុកម្មដោយសន្តិវិធី នៅទីលានប្រជាធិបតេយ្យ តាមគម្រោងដែលនឹងចាប់ផ្តើមនៅថ្ងៃទី០៧ ខែកញ្ញា ស្របតាមខ្លឹមសារ ***រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី*** និង ***សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ*** ។

វិធានការស្រដៀងគ្នានេះរបស់អាជ្ញាធររដ្ឋាភិបាល បានអនុវត្តយ៉ាងកំរោលលើសកម្មជនបរិស្ថាន **៣រូប** រួមមាន លោក **ថុន រដ្ឋា** កញ្ញា **ភួន កែវរស្មី** និងកញ្ញា **ឡុង គន្ធា** កាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ ដោយចាប់ឲ្យប្រឈមនឹងវិធានការតុលាការអយុត្តិធម៌ និងពន្ធនាគារ ខណៈពួកគាត់ធ្វើយុទ្ធនាការទាមទាររដ្ឋាភិបាល ឲ្យបញ្ឈប់ការលុបបឹងតាមោក នៅជាយក្រុងភ្នំពេញ ។ ជាពិសេស កាលពីថ្ងៃសុក្រ ទី៤ ខែកញ្ញា ការចាប់បោះគ្រវែងបែបប្រមាថដូចសត្វ លើស្ត្រីឈ្មោះ **សេខ ចាន់ថន** ដោយកងកម្លាំងសន្តិសុខខណ្ឌ៧មករា រាជធានីភ្នំពេញ ឲ្យស្ត្រីរងគ្រោះដួលដេកផ្ងារ ផ្ទៃកក្បាលខាងក្រោយបោកផ្ទប់ខ្លាំងលើផ្លូវកៅស៊ូរឹងដូចថ្ម គឺជាអំពើប៉ុនប៉ងឃាតកម្មជាក់ស្តែង លើអ្នកតស៊ូមតិអហិង្សា ដើម្បីសេរីភាព និងយុត្តិធម៌ ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ចាត់ទុកថា ចរន្តនៃទង្វើប្រើកម្លាំងយ៉ាងបំពានរបស់សមត្ថកិច្ច គឺជាចេតនាបែបផែនការយុទ្ធសាស្ត្រនយោបាយអសុចរិត ក្នុងការបន្តសង្កត់សង្កិនជ្រុលហួសហេតុ លើសិទ្ធិសេរីភាពស្របច្បាប់ នៃប្រជាពលរដ្ឋម្ចាស់នគរ ដែលមានកាតព្វកិច្ចពេញលេញក្នុងការសម្រេចលើជោគវាសនាជាតិ។

- *មាត្រា៣៥ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា « ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាង សកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។ សេចក្តីស្នើទាំងឡាយរបស់ ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ »* ។
- *មាត្រា៤១ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា « ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ »* ។
- *សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ១៩ ចែងថា « មនុស្សគ្រប់រូប មានសិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិ និងការសម្តែងមតិ ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាព ក្នុងការបញ្ចេញមតិ ដោយគ្មានការជ្រៀតជ្រែក និង សេរីភាពក្នុងការស្វែងរកការទទួល និងការផ្សព្វផ្សាយព័តមាន និងគំនិតនានា ដោយគ្មានព្រំដែន ទោះតាមរយៈ មធ្យោបាយសម្តែងមតិណាមួយក៏ដោយ»* ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ទាមទារដាច់ខាត ឲ្យរដ្ឋាភិបាល និងតុលាការកម្ពុជា ដោះលែងសកម្មជនទាំងអស់ដូចរៀបរាប់ខាងលើ ដោយគ្មានលក្ខខណ្ឌ រួមទាំងលោក **រ៉ុង ឈុន** យុវតី **ឈឿន ដារ៉ាវី** លោក **ហ៊ុន វណ្ណៈ** យុវតី **ស កន្និកា** លោក **សួង សុភ័ណ្ឌ** និងអ្នកឯទៀត ដើម្បីឲ្យពួកគាត់អាចអនុវត្តសិទ្ធិស្របច្បាប់ របស់ពួកគាត់ ដែលហ៊ានលះបង់សេចក្តីសុខផ្ទាល់ខ្លួន ជាពលរដ្ឋល្អថ្លៃថ្នូរ ក្នុងបុព្វហេតុបម្រើប្រយោជន៍សង្គមជាតិ ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ស្នើរដ្ឋសភាកម្ពុជា ធ្វើវិសោធនកម្មលុបចោល « **បទញុះញង់ឲ្យប្រព្រឹត្តបទល្មើស** » ត្រង់ជំពូកទី៣ ផ្នែកទី៣ នៃក្រមព្រហ្មទណ្ឌ លើករណីនៃសេរីភាពបញ្ចេញមតិ និងការសម្តែងមតិ ជាសាធារណៈ និង សេរីភាពនៃការស្រាវជ្រាវនិងផ្សព្វផ្សាយព័ត៌មាននិងគំនិតយោបល់ ទោះតាមមធ្យោបាយណាក៏ដោយ ដើម្បីបើឱកាសឲ្យកាន់តែទូលាយ ដល់ប្រជាពលរដ្ឋទូទៅ អាចចូលរួមចំណែកកែលម្អសង្គម ។ បើរដ្ឋាភិបាល និងរដ្ឋសភា នៅតែខំបង្រ្កួញលំហសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ នោះអង្គការរដ្ឋនឹងក្លាយទៅជាឧបករណ៍អំណាចរបស់ក្រុមបុគ្គលប៉ុណ្ណោះ ។

**ប្រធានប្រតិបត្តិ**

**ទូច វិបុល**